International Labour Organization

Australian Aid

# គោលការណ៍ណែនាំស្តីពីការដោះស្រាយវិវាទរបស់ពលករទេសន្តរប្រវេសន៍

## លទ្ធភាពទទួលបានយុត្តិធម៌ និងការផ្តល់ដំណោះស្រាយចំពោះបណ្តឹងរបស់ពលករទេសន្តរប្រវេសន៍ក្លាយជាការពិត

គោលការណ៍ណែនាំសម្រាប់ដោះស្រាយវិវាទរបស់ពលករទេសន្តរប្រវេសន៍មានគោលបំណងផ្តល់ជាមូលដ្ឋានសម្រាប់ឱ្យមន្រ្តីទទួលបន្ទុកការងារបុគ្គលិករបស់មណ្ឌលធនធានពលករទេសន្តរប្រវេសន៍ និងដៃគូត្រីភាគីផ្សេងទៀតអាចប្រើប្រាស់ឯកសារនេះសម្រាប់ជាមូលដ្ឋាន និងអំណះអំណាង នៅពេលស្វែងរកដំណោះស្រាយ និងគាំទ្រដល់ពលករទេសន្តរប្រវេសន៍ ឬអ្នកតំណាងក្នុងដំណើរការដោះស្រាយវិវាទ។

ឯកសារនេះពិពណ៌នាអំពីចំណុចសំខាន់ៗក្នុងដំណើរការដោះស្រាយវិវាទ និងការផ្តល់ព័ត៌មានដល់ពលករទេសន្តរប្រវេសន៍ដែលជាដើមបណ្តឹង។

## ការដោះស្រាយបណ្តឹងមានសារសំខាន់យ៉ាងខ្លាំង

**ពលករគ្រប់រូប រាប់បញ្ចូលទាំងពលករទេសន្តរប្រវេសន៍ផងដែរ មានសិទ្ធិទទួលបានលក្ខខណ្ឌការងារសមរម្យ និងមានសិទ្ធិដាក់ពាក្យបណ្តឹង ប្រសិនបើពួកគេទទួលរងការកេងប្រវ័ញ្ច ឬការរំលោភបំពាន។**

គោលការណ៍ណែនាំស្តីពីការដោះស្រាយវិវាទនេះត្រូវបានរៀបចំឡើងដើម្បីផ្តល់ដំណោះស្រាយនិងភាពយុត្តិធម៌ឱ្យបានទាន់ពេលវេលាប្រកបដោយតម្លាភាពនិងឆ្លើយតបចំពោះតម្រូវការយេនឌ័រដល់ពលករទេសន្តរប្រវេសន៍ដោយផ្អែកតាមសិទ្ធិជាមូលដ្ឋានរបស់ពួកគេ។គោលការណ៍ណែនាំនេះបញ្ជាក់ច្បាស់ផងដែរអំពីសារសំខាន់ផ្តល់ការណែនាំដល់មន្ត្រីក្នុងការដោះស្រាយបណ្តឹងដើម្បីធានាឱ្យមានលទ្ធផលនិងដំណោះស្រាយស្របតាមច្បាប់ស្តីពីការងារ អនុក្រឹត្យ ប្រកាស លិខិតបទដ្ឋានគតិយុត្ត ស្តីពីការងាររបស់ប្រទេសកម្ពុជា និងបទដ្ឋានការងារអន្តរជាតិនានា និងពុំរឹតត្បិតលើការប្រើប្រាស់យន្តការដោះស្រាយបណ្តឹងតវ៉ាផ្សេងទៀតនោះឡើយ។



### ពលករទេសន្តរប្រវេសន៍គ្រប់រូបសុទ្ធតែអាចដាក់ពាក្យបណ្តឹងបាន

សមាជិកគ្រួសាររបស់ពលករទេសន្តរប្រវេសន៍ ក៏អាចចាប់ផ្តើមដំណើរការដាក់ពាក្យបណ្តឹងផងដែរ ជាពិសេសពលករទេសន្តរប្រវេសន៍ដែលកំពុងនៅក្រៅប្រទេសនៅឡើយ។

ពលករទេសន្តរប្រវេសន៍ សមាជិកគ្រួសាររបស់ពួកគេ ឬតំណាងដែលត្រូវបានជ្រើសរើសរបស់ពួកគេសុទ្ធតែអាចដាក់ពាក្យបណ្តឹងតាមរយៈដំណើរការដោះស្រាយវិវាទនេះ។ពាក្យបណ្តឹងអាចដាក់ជាលក្ខណៈបុគ្គល ឬជាបណ្តឹងជាក្រុម។

## ព្រឹត្តិការណ៍អ្វីមួយ ឬបុគ្គលណាម្នាក់ ដែលពាក់ព័ន្ធនៅក្នុងដំណើរការទេសន្តរប្រវេសន៍ សុទ្ធតែអាចជាមុខសញ្ញានៃពាក្យបណ្តឹង។

- ពាក្យបណ្តឹងអាចផ្តោតលើឥរិយាបថ ឬការប្រព្រឹត្តរបស់បុគ្គលណាម្នាក់ ឬជាស្ថានភាពអ្វីមួយដែលកើតឡើងក្នុងអំឡុងពេលនៃការធ្វើទេសន្តរប្រវេសន៍ ដូចជា ការទូទាត់ប្រាក់ឈ្នួលមិនគ្រប់ ឬការដកហូតលិខិតឆ្លងដែនជាដើម។
- ពួកគេក៏អាចដាក់ពាក្យបណ្តឹងចំពោះបុគ្គលណាម្នាក់នៅក្នុងដំណើរការទេសន្តរប្រវេសន៍ផងដែរដូចជាភ្នាក់ងារជ្រើសរើសពលករនិយោជក ឬមន្ត្រីទទួលបន្ទុកទេសន្តរប្រវេសន៍នៅក្នុងប្រទេសកម្ពុជាឬនៅក្នុងប្រទេសគោលដៅ ក្នុងករណីរំលោភបំពាន ឬការកេងបន្លំផ្សេងៗ។
- គោលការណ៍ណែនាំនេះផ្តល់ដំបូន្មានដល់មន្ត្រីពាក់ព័ន្ធអំពីរបៀបដោះស្រាយបណ្តឹងនៅក្នុងប្រទេសគោលដៅ។ប្រភេទពាក្យបណ្តឹងដែលធ្លាប់មានញឹកញាប់ជាងគេរួមមានពាក្យបណ្តឹងអំពីការបើកប្រាក់ឈ្នួលមិនគ្រប់ ឬការពុំបើកប្រាក់ឈ្នួលឱ្យ ការដកហូតទុកឯកសារសម្គាល់អត្តសញ្ញាណ និងការពន្យារពេលផ្តល់ការងារឱ្យធ្វើ / មិនផ្តល់ការងារឱ្យធ្វើជាដើម។

# គោលការណ៍ណែនាំស្តីពីការដោះស្រាយវិវាទរបស់ ពលករទេសន្តរប្រវេសន៍

## គេអាចដាក់ពាក្យបណ្តឹងនៅពេលណាក៏បាន ក្នុងអំឡុងដំណើរការទេសន្តរប្រវេសន៍

ជាការល្អ ពាក្យបណ្តឹងគួរដាក់ឱ្យបានឆាប់បំផុត ក្រោយពេលដែលមានបញ្ហាកើតមានឡើង ប៉ុន្តែគេក៏អាចដាក់ពាក្យបណ្តឹងបាន នៅពេលដែលពលករទេសន្តរប្រវេសន៍វិលត្រឡប់មកស្រុកកំណើតវិញ។

នៅពេលណាក៏ដោយនៅពេលដែលមានមូលហេតុដាក់ពាក្យបណ្តឹង ឧទាហរណ៍ការយកថ្លៃសេវាច្រើនលើសលប់ ការបំពានកិច្ចសន្យា ការផ្សាយពាណិជ្ជកម្មបែបបន្លំ ឬធ្វើឱ្យមានការភាន់ច្រឡំ ដែលជួបប្រទះនៅពេលណាមួយក្នុងដំណើរការទេសន្តរប្រវេសន៍ នោះគេអាចដាក់ពាក្យបណ្តឹងបាន។

## មណ្ឌលធនធានទេសន្តរប្រវេសន៍ មន្ទីរការងារ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សុទ្ធតែអាចទទួលពាក្យបណ្តឹងយកទៅធ្វើការដោះស្រាយ។

### អ្នកស្វែងរកការគាំទ្រដល់ពលករទេសន្តរប្រវេសន៍ សង្គមស៊ីវិល ឬជំនួយផ្លូវច្បាប់ដទៃទៀត ក៏អាចជួយដល់ការដាក់ពាក្យបណ្តឹងផងដែរ។

នៅពេលដែលមានបណ្តឹងណាមួយកើតមានឡើង ពលករទេសន្តរប្រវេសន៍ ឬសមាជិកគ្រួសារ អាចដាក់ពាក្យបណ្តឹងនេះនៅមណ្ឌលធនធានទេសន្តរប្រវេសន៍ឬដាក់ពាក្យបណ្តឹងដោយផ្ទាល់ទៅកាន់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ អ្នកដាក់ពាក្យបណ្តឹងត្រូវបំពេញទម្រង់ ហើយអ្នកជួយគាំទ្រដល់ពលករទេសន្តរប្រវេសន៍ អាចជួយបំពេញឯកសារទាំងនេះបាន។

## គោលការណ៍ណែនាំស្តីពីការដោះស្រាយវិវាទរៀបរាប់ពីដំណើរការសម្រាប់ឆ្លើយតបចំពោះពាក្យបណ្តឹង

### នៅក្នុងច្បាប់ មានបញ្ញត្តិចែងពីដំណើរការសម្រាប់ដោះស្រាយពាក្យបណ្តឹង។

ការវាយតម្លៃលើពាក្យបណ្តឹងទាំងអស់ គួរធ្វើឡើង ដោយប្រើប្រាស់ដំណើរការមួយដែលមានការអញ្ជើញភាគីដែលពាក់ព័ន្ធឱ្យចូលរួមធ្វើការពិភាក្សាពាក្យបណ្តឹងនេះដាច់ដោយឡែកពីគ្នាជាមួយនឹងមន្ត្រីដោះស្រាយបណ្តឹងក្នុងមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈឬក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយសង្ឃឹមថា ភាគីទាំងសងខាងនឹងឯកភាពរួមគ្នាលើលទ្ធផលដែលកើតចេញពីការផ្សះផ្សា។

ប្រសិនបើគេមិនអាចសះជានៅកម្រិតខេត្តទេ ពាក្យបណ្តឹងនេះនឹងត្រូវបញ្ជូនទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីចាត់ការបន្ត។

**រូប ១៖** សម្រាប់ការដោះស្រាយបណ្តឹងរបស់ពលករទេសន្តរប្រវេសន៍ដែលបានដាក់ពាក្យបណ្តឹងតាមរយៈ មណ្ឌលធនធានពលករទេសន្តរប្រវេសន៍ (MRC)

**ដ្យាក្រាមបង្ហាញពីដំណើរការដោះស្រាយបណ្តឹង៖**



# រូប ២ ៖ ជំហានសម្រាប់ការដោះស្រាយបណ្ដឹង

របស់ពលករទេសន្តរប្រវេសន៍ ដែលបានដាក់ពាក្យបណ្ដឹងតាមរយៈ មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ



# រូប ៣ ៖ ជំហានសម្រាប់ការដោះស្រាយបណ្តឹង

## របស់ពលករទេសន្តរប្រវេសន៍ ដែលបានដាក់ពាក្យបណ្តឹងតាមរយៈ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ




**TRIANGLE IN ASEAN**
Phnom Penh Centre Building F, 2nd Floor,
Conor Sihanouk and Sothearos Boulevard
Phnom Penh Cambodia

T: +855 23 220 817
F:+855 23 221 536
E: VORN@ILO.ORG